# បិសាចស្នេហ៍



យ្បង ស្បដា

# បិសាចក្រមុំ

យួង សូជា

# បិសាចក្រមុំ

ចងក្រងដោយ : យួង សូដា
រចនាក្របដោយ : ទិត្យ ដែន
គេហទំព័រហ្វេសប៊ុក : Yuong So Da
ទូរស័ព្ទ : 086 83 26 20

*អ្នកអានមានសិទ្ធិដើម្បីចម្លង ផ្សព្វផ្សាយ ឬនកស្រង់បានដោយសេរី ដោយមិនចាំបាច់មានការអនុញ្ញាតពីអ្នកនិពន្ធ។ ប៉ុន្តែត្រូវគោរព នូវលក្ខខណ្ឌពីរយ៉ាង ទីមួយបញ្ជាក់ប្រភព និង ទីពីរមិនយកទៅលក់ដូរ។*

*ស្នាដៃនេះ ត្រូវបាននិពន្ធឡើង សម្រាប់ចែកចាយដោយឥតគិតថ្លៃ ទៅកាន់អ្នកដែលចង់អាន និងបណ្ណាល័យមួយចំនួន ដើម្បីបម្រើប្រយោជន៍សាធារណជន និងសិស្សានុសិស្ស។*

# មាតិកា

អារម្ភកថា
លួចស្នេហ៍ ........ ២
សែនស្រឡាញ់ ........ ៤
ភ្លើងតណ្ហា ........ ៧
ពិតទេពាក្យពៅ? ........ ១០
បើបងជាគ្រូខ្ញុំ ........ ១៣
ត្រឹមជាស្រមៃ ........ ១៦
ស្ដាយសុបិន ........ ១៨
ចន្ទរះឥតន័យ ........ ២២
ភ្លៀងធ្លាក់ ........ ២៥
បាត់ម្ចាស់ស្នេហ៍ ........ ២៨
ស្រមោលនារី ........ ៣០
ស្ទឹងកម្ម ........ ៣៣

ផ្កាស្មៅ ........................................ ៣៥
ថ្ងៃលិចនៅចំការឈូក ........................ ៣៧
ខែរងា ........................................ ៤០
តំណែងតួរង ........................................ ៤២
នាមភ្ញៀវការ ........................................ ៤៤
បងស្ញើចឡូនណាស់ ........................ ៤៧
ចិត្តចើក ........................................ ៤៩
បិសាចក្រមុំ ........................................ ៥១
ក្មេងនារី ........................................ ៥៤
ថ្នាំ ........................................ ៥៦
ជនសំណល់ ........................................ ៥៨
ស្ដាយចិត្តកម្លោះ ........................ ៦០
ស្មោះប៉ុណ្ណាទៀត? ........................ ៦៣
មិនមែនសង្សារបងទេ ........................ ៦៥
កុំសូមទោសអី ! ........................ ៦៨

# អារម្ភកថា

សៀវភៅ "បិសាចក្រមុំ" គឺជាស្រោះទឹកភ្នែក ដែលហូរធ្លាក់ពីកំពូលដួងចិត្តកវី ចាក់ចូលទៅក្នុងមហាសមុទ្រទុក្ខដ៏ធំ ដែលមានសភាពខ្មៅគគ្រិចដូចភក់ផ្សាំ។ រសជាតិល្វីចាប់ងដែលៗ នៅក្នុងពែងស្នេហា ដែលឆុងយ៉ាងឈ្ងុយ ដោយប្រាមដែងដ៏ទន់ត្រលន របស់ក្រមុំៗ បានសណ្តំកវីឱ្យស្រវឹងស្រុលស្រែង ធ្វើកំពប់ទឹកខ្មៅ ហូរស្រោចប្រតេកប្រភាកពាសពេញ ទំព័រទាំងឡាយនៃសៀវភៅនេះ ដោយមិនដឹងខ្លួន។

ដូច្នេះ ក្នុងគំនិតរបស់កវីពុំហ៊ានស្រមៃថា អ្នកអាននឹងទទួលបានចំណេះដឹងជាដុំកំភួន ពីសៀវភៅមួយ

ក្បាលនេះឡើយ ស្បិតគ្រប់ទំព័រ និងដាមតែស្នាមខ្ទិចខ្ទៀក នៃមនោសញ្ចេតនាគូសចេញពីប៉ាកកា ដែលរយះបាក់ផងទៅហើយ។ និយាយដោយខ្លី វាកំដរមនោសញ្ចេតនា ច្រើនដាងកំដរគំនិតទស្សនៈ។

ឧទ្ទិសជូនស្នេហ៍ក្បត់ !

បិសាចក្រមុំ

ទោះបីបង
យកភ្នំធ្វើជាប៉ាកកា
យកផែនដីធ្វើជាក្រដាស
យកមហាសមុទ្រធ្វើជាទឹកខ្មៅ
ក៏បងមិនអាចពិពណ៌នាឱ្យអស់
នូវសេចក្ដីឈឺចាប់
ក្នុងបេះដូងបង
បានដែរៗ

# លួចស្នេហ៍

ចង់ទុកពាក្យពេចន៍លើមេឃា
យកផ្កាយធ្វើជាតួអក្ខរា
ថាបងលួចស្នេហ៍លើជីវ៉ា
តើគិតយ៉ាងណាស្រស់ចរណៃ។

ទឹកកាលរាត្រីចន្ទពេញវង់
ហឫទ័យបងលង់សម្រស់ស្រី
ទាស់ត្រង់ឆ្ងាយគ្នាដូចមេឃដី
បានត្រឹមស្រមៃមើលរូបថត៕

បើបេះដូងបងអាចនិយាយជាសំឡេងមកក្រៅ
ដូចបបូរមាត់បាន
វានឹងនិយាយពាក្យមួយឃ្លាមុនគេ
ប្រាប់ទៅអូនថា
“ បងស្រឡាញ់អូនណាស់ ” ។

*ឈួន សុជា*

# សែនស្រឡាញ់

សែនស្រឡាញ់ ក្នាញ់ស្រណោះ ស្រស់ប្រិមប្រិយ
សាច់សខ្ចី ដៃស្រលន ខ្លួនស្រលះ
ឫកអឹមអៀន រៀនអែនអន ទន់ចង្កេះ
ស្លៀកសំពែះ ច្បាស់រន្ធផ្ចិត ខិតខើចក្រោមៗ

រាងច្រឡឹង ភ្លឹងគ្មានភ្លី ទីណាមួយ
ទ្រូងរញ្ជួយ ព្រួយក្រែងព្រាត់ បាត់រូបឆោម
ចង់ប្រឡូក លូកប្រឡែង លេងប្រលោម
បើសិនព្រម សូមប្រណី ស្ដីវាចាៗ

បានយល់ភក្ត្រ ជាក់យល់ច្បាស់ ប៉ះគូព្រេង
សក់ទង់ដែង វែងគ្របខ្នង បងស្នេហា
ចង់ដឹកដៃ ស្រីដើរឆ្លង ដងព្រឹក្សា
ងូតទឹកថ្លា ផាទឹកជ្រោះ ហួសព្រៃជ្រៅៗ

រួចឡើងភ្នំ កំពូលស្រួច ក្ដួចខ្យល់បក់
ទោះដង្ហក់ ស្រក់ញើសជ័រ ក៏ស្ម័គ្រទៅ
នាំអូនក្សាន្ត ហានសប្បាយ ឆ្ងាយសោកសៅ
ថ្មមពាលពៅ នៅពីរនាក់ រក្សាស្នេហ៍៕

*ឃួង សូផា*

ខ្ញុំចង់តែ
កាច់បំបាក់ចុងប៉ាកកាចោល
ហើយខ្ចប់ក្រដាសបោះចូលទៅក្នុងធុងសំរាម
ប្រលោមលោក
ព្រោះថា
ខ្ញុំមិនអាចពិពណ៌នា
ពីសម្រស់ដ៏ស្រស់ត្រកាលរបស់នាងឱ្យសមសោះឡើយ
ធម្មជាតិដ៏អយុត្តិធម៌
ហាក់ប្រគល់សម្រស់ទុកឱ្យតែរូបនាងម្នាក់គត់ៗ

បិសាចក្រមុំ

# ភ្លើងតណ្ហា

ភ្លើងពណ៌រាត្រីឆ្លុះដងខ្លួន
តណ្ហាអង្រួនដួងព្រលឹង
រាងរៅស្រលនសាច់សភ្លឹង
ចង់តែស្រវឹងលើប្រាណស្រីៗ

ភក្ត្រាស្រស់ណាស់ម្ចាស់ស្នេហ៍ស្នង
ញញឹមម្តងៗបងអរភ័យ
ចង់ដៅស្នាមថើបភ្ជាប់និស្ស័យ
បើកទំព័រថ្មីក្តីស្នេហាៗ

មើលចុះទ្រូងអូនពើងណែនក្តន់
កូនភ្នំតូចតន់គួរទស្សនា
ចង់ឆ្វែលក្រឡឹងភ្នំជីរ៉ា
បេះផ្លែផល្លាចាប់ពមភ្លក់ៗ

*យួង សុខា*

រួចហួសទៅលេងជ្រោះជ្រលង
កាច់ផ្កាមួយទងថើបជញ្ជក់
ផ្កាអើយស្មៅគ្របដុះក្នុងភក់
ស្រទាប់ជ្រលក់ដក់សើមទឹកៗ

ចង់អុំទូកលេងក្នុងគង្គា
ពីរនាក់ពុំងាយប់ទល់ព្រឹក
ស្ដាប់ខ្យល់ថ្ងូចថ្ងូរស្រមៃនឹក
មើលភ្លៀងសន្ធឹកលិចវាលស្រែៗ

ស៊ូនៅវេងាឱបជើងដៃ
ទោះជាត្រូវក្ស័យចោលក្លិនស្នេហ៍
មិនស្ដាយអ្វីសោះសូមឱ្យតែ
បានរស់ស្និទ្ធក្បែរបង្គងស្រីៗ៕

ស្នេហាបានបិទភ្នែកបង
ហើយដឹកដៃទៅរកមាត់ជ្រោះៗ
បងបានដឹងយ៉ាងច្បាស់
តែបងនៅតែបណ្តោយឱ្យជើងទាំងពីរ
ដើរទៅមុខជានិច្ចៗ
បើទោះជាបងត្រូវស្លាប់ បងក៏អស់ចិត្តដែរ
ព្រោះថាសំឡេងទឹកជ្រោះដ៏ពីរោះរណ្តំ
និងបុប្ផជាតិដ៏ក្រអូបឈ្ងុយឈ្ងប់
គឺជាសេចក្តីសុខកំពូលដែលបងប្រាថ្នាចង់យល់
មុននឹងសេចក្តីមរណៈមកដល់ៗ

*ឃ្លួង សុជា*

# ពិតទេពាក្យពៅ?

ពិតទេពាក្យពៅថានឹករូបបង
ហើយមានបំណងប៉ងចង់ជួបមុខ
ឬគ្រាន់ជាល្បែងឱ្យបងកើតទុក្ខ
ឬជាក្ដីសុខដែលស្ងួនផ្ដល់ឱ្យៗ

ពិតទេពាក្យពៅថាឆាប់ទន់ចិត្ត
ដំបូងអាណិតទើបស្រឡាញ់ក្រោយ
ឬគ្រាន់ជាពាក្យលួងលោមឱ្យស្បើយ
ឬជាចម្លើយពីបេះដូងស្មោះៗ

ពិតទេពាក្យពៅថាចិត្តស្រីៗ
ឆ្លើយ "ទេ" យ៉ាងខ្លីចំពោះប្រុសៗ
ពុំមែនមិនផ្ដល់ឱកាសអ្វីសោះ
នៅតែស្រណោះមានចិត្តគិតដែរៗ

បើជាពាក្យពិតរៀមសូមផ្ដិតទុក
ចងជាទំនុកកំណាព្យក្ដីស្នេហ៍
ឆ្លាក់ចារក្នុងទ្រូងគ្មានថ្ងៃប្រួលប្រែ
បីបមថ្នមថែលុះសូន្យសង្ខារៗ

តែបើជាពាក្យកុហកទៅវិញ
រៀមច្បាស់ទោម្នេញទោមនស្សសោកា
ជីវិតពិតរស់ក្នុងគុកស្នេហា
សូមពៅមេត្តាករីអភ័ព្វៗ៕

*យ្សួង ស្លូងា*

ចន្ទ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ សៅរ៍ អាទិត្យ...
ថ្ងៃណាក៏ស្រស់បំព្រងប្លែកគ្នាដែរ
នៅពេលដែលមាននាងនៅក្បែរ
ហាក់ដូចជាខ្ញុំបានដើរកម្សាន្តនៅតាមទីក្រុងនានា
ដូច្នោះៗ
ប៉ុន្តែពេលដែលគ្មាននាងនៅក្បែរ
ថ្ងៃណាក៏ដូចថ្ងៃណា យប់ណាក៏ដូចយប់ណា
ខ្លួនខ្ញុំហាក់ជាប់ឃុំនៅក្នុងគុកមួយកន្លែងៗ

បិសាចក្រមុំ

# បេីបងជាក្រុក

បាត់អូនដូចបាត់មនុស្សមួយផែនដី
រៀងរាល់រាត្រីសេីចលាយទឹកភ្នែក
ចង់នៅក្បែរប្រាណចង់នៅជជែក
កំប្លែងរំលែកកម្ចាត់ទុក្ខាៗ

អូនឆ្លេីយមួយម៉ាត់តែបាត់ទល់ភ្លឺ
បងងងុយឈឺព្រោះចាំមេីលសារ
បងនឹកខ្លាំងជ្រុលអូននឹកធម្មតា
តែបងមិនថាមិនស្តីអូនឡេីយៗ

នឹកព្រោះស្រឡាញ់ក្តាញ់ព្រោះប្រាថ្នា
សេចក្តីស្នេហាធំឥតកោះត្រេីយ
បេះដូងបងនេះបេីប្រគល់ហេីយ
មិនប្រែកន្តេីយលុះសូន្យជីវិតៗ

*យ្សួង ស្ទូងា*

ខ្លួនបងអន់ណាស់អន់ជាងខ្មើយឱប
ខ្មើយអ្នូនមានភ័ព្វអ្នូនឱបជាប់ស្និត
រូបបងនៅឆ្ងាយត្រឹមស្រមៃគិត
ខ្មើយឱបនៅជិតបានស្និទ្ធប្រាណស្រីៗ

បើបងជាគ្រុឌមានស្លាបហើរហោះ
គ្មានខ្លាចអ្វីសោះហោះជ្រែកមេឃដី
ឆ្លងមហាសមុទ្រផុតទ្វីបលោកិយ
សោយសុខសិរីក្នុងវិមានសួគ៌ៗ។

បងស្អប់អូនណាស់!

ហេតុអ្វី?

ព្រោះអូនធ្វើឱ្យបងនឹករហូតលែងចង់ឮអ្វីទាំងអស់

ក្រៅពីឈ្មោះអូន

លែងចង់ជួបអ្វីទាំងអស់

ក្រៅពីរូបអូនៗ

បេះដូងបងធ្លាក់ក្នុងអាណានិគមអូនហើយៗ

*ឈួង សូឌា*

# ត្រឹមជាស្រមៃ

ឱដួងព្រះចន្ទ រស្មីសុវណ្ណ
នាថ្ងៃបូណ៌មី ពួដ៏នភា
លម្អរាត្រី ពេញដោយហឫទ័យ
ស្លូតបូតមេត្តា។

ឱដួងព្រះខែ មាននូវមន្តស្នេហ៍
ផ្កាប់ផ្គន់នេត្រា មុខមូលក្រឡង់
ញញឹមភាសា ចិត្តចង់ប្រាប់ថា
សាសងមេត្រី។

ឱដួងចន្ទ្រា ហាក់នៅជិតគ្នា
តែឆ្ងាយអាល័យ ហាក់ដូចការពិត
តែជាស្រមៃ ហាក់មាននិស្ស័យ
តែគ្មានវាសនា៕

ត្រឹមមានអូននៅក្នុងក្តីស្រមៃ
បងស្កប់ស្កល់ចិត្តណាស់ទៅហើយៗ
បងមិនប្រាថ្នាកាច់ផ្ការបស់អូនឱ្យស្រពោនស្វិតទេៗ
អូនថៃទុកសម្រាប់បុរសផ្សេងចុះ!

*យួន សុជា*

# ស្តាយសុបិន

ម៉ោងបួនទៀបភ្លឺភ្ញាក់ចំប្រប់
ឱរាតឹងថប់លាយទុក្ខព្រួយ
សុបិនឃើញស្នេហ៍យើងតែមួយ
កក្រើករញ្ជួយក្រោមដួងខែ។

សុបិនឃើញស្ងួនមកជួបបង
រំភើបកន្លងក្នុងភពស្នេហ៍
បងលូកហត្ថាថ្នាក់ថ្នមថៃ
ពៅអូនឪនាងបែរអឹមអៀនបង។

សុបិនច្បាស់ណាស់ពៅញញឹម
តក្រោប៉ប្រិមស្រស់កន្លង
ខ្សែភ្នែកបាញ់ចំបងម្តងៗ
ភ្ញាក់ផងភ័យផងព្រោះភ្នែកមុត។

រៀមលើកត្រកងបង្វិលប្រាណ
ស្រស់ស្រីកល្យាណអររន្ធត់
បណ្ដោយតាមតែបងម្នាក់គត់
មិនប្រកែករត់នៅស្មោះស្ម័គ្រៗ

សុបិនឮច្បាស់ក្នុងត្រចៀក
ពៅអូនឱនកៀកងាកឲ្យបដាក់
ថាអូនស្រឡាញ់បងតែម្នាក់
លេបហើយមិនខ្ជាក់ចោលជាន់ឈ្លីៗ

ស្រណោះពាក្យអូនពីរោះក្រៃ
ស្រណោះអត្ថន័យស្មោះឥតពីរ
ស្រណោះក្លិនក្លែបថើបរក់រី
រីរនារីប្រគល់ស្នេហ៍ៗ

*យល្លង ស្ងួសា*

ភ្ញាក់ពីសុបិនបងចំបែង
ស្តាយហួសក្តីថ្លែងទ្រូងគ្មានល្ហែ
ចង់ឱ្យសុបិននេះនៅតែ
បន្តរាប់ខែភាគវែងឆ្ងាយៗ

តែទោះសុបិនរសាត់ទៅ
ក៏ហឫទ័យនៅមិនរសាយ
ខំតែងកំណាព្យអធិប្បាយ
ប្រាប់ពីក្តីស្តាយដល់ពៅបង៕

រាល់ភ្នាក់ពីដំណេក
បងមើលឃើញតែស្រមោលនៃរង់ភក្ត្រអូន
មុននរណាទាំងអស់
បងឮសូរតែសំនៀងល្វើយៗយ៉ាងពីរោះរបស់អូន
មុនសំឡេងអ្វីទាំងអស់ៗ
ខ្លួនបងហាក់ស្រាលអណ្តែតឡើងភ្លាម
ចាកចេញពីកន្លែងដែលបងប្រះខ្លួនគេង
ទៅក្នុងលំហអាកាស
រួចក៏សំដៅកាន់ទីអនុស្សាវរីយ៍នានា
ដែលយើងធ្លាប់ញញឹម
ធ្លាប់សើចសប្បាយ
ធ្លាប់សាសងដោយពាក្យពេចន៍ស្នេហា
ធ្លាប់កាន់ដៃគ្នារត់ប្រឡែងលេងនឹងធម្មជាតិ
ក្រោមអរុណោទ័យដ៏ក្រហមភ្លឺថ្លាៗ

*យួង សូនា*

# ចន្ទរះឥតន័យ

ភ្លៀងធ្លាក់ថ្មីៗដីប៉ប៉ាច់
អង្គុយដូចស្ដេចលើគុម្ពស្មៅ
តែចិត្តជាប់ទោសខ្មោះហ្មងសៅ
រឿងក្ដីស្នេហ៍ពៅកោះហៅក្ដែងៗ

រាត្រីនេះហើយយើងណាត់គ្នា
ឥឡូវចន្ទ្រារះតែឯង
ចន្ទដប់ប្រាំកើតអើតក្នុងផ្សែង
ខ្មាសមេឃហួសថ្លែងភ្លឺស្រអាប់ៗ

ចន្ទអើយសូមឈប់ធ្វើសាក្សី
ព្រោះពាក្យពេចន៍ស្រីឥតស្ដុតាងស្រាប់
ពាក្យទើបនឹងឱ្យខ្ញុំឈឺចាប់
ពាក្យដែលថ្លែងប្រាប់ទាំងណែនចិត្តៗ

ពពកខ្មៅអើយបាំងចន្ទទៅ
កុំឱ្យរះនៅឃើញអតីត
តែសូមចន្ទកុំមានគំនិត
ថាខ្ញុំនេះពិតស្អប់ឱ្យសោះៗ

ខ្យល់អើយឈប់បក់លួងលោមខ្ញុំ
រាត្រីនេះសុំឃុំស្រណោះ
កុំបក់នាំស្លូតទឹកភ្នែកអស់
ឱ្យហូរមកចុះកើតជាស្ទឹងៗ

ពេលកើតជាស្ទឹងហូរជន់លិច
ឱ្យទុក្ខលង់ខ្មោចលែងយល់ដឹង
ភ្លៀងអើយកុំរាំងសូមអ្នកខឹង
លេងមួយទំហឹងលិចខ្ញុំផងៗ។

*យ្សូង ស្ទូងា*

ប្រសិនបើផែនដីអាចវិលថយក្រោយបាន
បងចង់ក្លាយជាកូនក្មេងរហូតទៅៗ
ប្រសិនបើព្រះអាទិត្យអាចពន្លត់រស្មីបាន
បងចង់ឱ្យចក្រវាឡនេះងងឹតរហូតទៅៗ
ប្រសិនបើរូបកាយមនុស្សស្លាប់
ហើយអាចរស់វិញវិញស្អែក
បងចង់ស្លាប់នៅក្នុងថ្ងៃនេះៗ
បងមិនខ្វល់ថានឹងមានរឿងអ្វីកើតឡើងឡើយ
បងសុំត្រឹមតែអាចដកយករូបអូន
ចេញពីការចងចាំរបស់បងប៉ុណ្ណោះៗ

ប៉ិសាចក្រមុំ

# ភ្លៀងធ្លាក់

ភ្លៀងធ្លាក់មិនឈប់ ពីព្រឹកទល់យប់
សង្កត់ទីក្រុង សង្កត់ទាំងចិត្ត
ឱ្យស្អិតជាប់ផុង ជាប់រឿងឆោតល្ងង់
ទុក្ខសោកឥតល្ហែៗ

ភ្លៀងធ្លាក់លើសលន់ ទន្លេស្ទឹងជន់
លិចអស់វាលស្រែ ដូចផ្ទាំងគំនូរ
បងគូរជូនស្នេហ៍ ពេលនេះប្រួលប្រែ
ព្រាត់ប្រាសខានយល់ៗ

ភ្លៀងធ្លាក់សន្ធឹក ឈើជ្រុះសន្លឹក
រសាត់តាមខ្យល់ ធ្លាក់ក្បួចតាមទឹក
ព្រាត់ឆ្ងាយពីគល់ សង្ឃឹមធ្លាប់ផ្តល់
សល់តែស្រមៃៗ

*ឈួង សួងា*

ភ្លៀងធ្លាក់បន្ទរ សំនៀងថ្ងូចថ្ងូរ
ដូចត្បូងតន្ត្រី ទឹកដល់ចម្រៀង
ច្រៀងបំពេរស្រី ពេលនេះបទថ្មី
ច្រៀងលួងខ្លួនឯងៗ

ភ្លៀងធ្លាក់ចំហាយ រងាររូបកាយ
កណ្ដោចកណ្ដែង ពុំដឹងថ្ងៃណា
មេឃស្រលះផ្សេង ឃើញច្បាស់ស្បូវសែង
រះក្នុងភពស្នេហ៍ៗ៕

ភ្លៀង... ជាវេលាមួយដែល
ធ្វើឱ្យបេះដូងបងកក់ក្ដៅជាងវេលាណាទាំងអស់ៗ
ដំណក់ទឹកភ្លៀងជាសំឡេងតន្ត្រីដ៏ពីរោះម៉្យាង
ដែលបងចង់តែស្ដាប់វាមិនចេះជិនណាយ
ឯផ្គររន្ទះជាពន្លឺមួយដ៏រុងរឿង
ដែលបងចង់តែមើលវាម្ដងហើយម្ដងទៀតៗ
បើវេលាភ្លៀងធ្លាក់
ទ្រូងបងមានប្រាណអូននៅក្បែរទៀតនោះ
ម្ចាស់ចិត្តបងអើយ!
តើសេចក្ដីសុខឯណា
អាចមកប្រៀបផ្ទឹមនឹងស្នេហាដ៏កក់ក្ដៅរបស់យើង
ក្នុងគ្រានោះទៀតទៅ?

*យួង សូនា*

# បាត់ម្ចាស់ស្នេហ៍

ឈប់ឈន់សែនស្ងាត់ ព្នៃតែកូនក្អាត់
ស្រែកតាមវាលស្រែ រីសត្វចង្រិត
ទួញយំណាស់ដែរ ដ្បិតបាត់ម្ចាស់ស្នេហ៍
ខាងយល់តក្រោះៗ

លុះភ្លៀងចាប់ធ្លាក់ រងឹងរឹតញ័រញាក់
សព្វអស់កាយា បេះដូងផ្តើមគ្រុន
គ្មានម្ចាស់រក្សា ឱ្យធ្វើយ៉ាងណា
បើអូនឆ្ងាយក្រៃៗ៕

តើឱ្យខ្ញុំជួសជុលបេះដូងដោយរបៀបណា
បើម្ចាស់របស់វាលែងនៅជិតទៅហើយ ?

*ឈួង សុងា*

# ស្រមោលនារី

នារីដូចស្រមោល
ដែលអន្ទោលយោលតាមប្រាណ
ដេញចាប់ ចាប់មិនបាន
យូរប៉ុន្មានបានត្រឹមហត់ៗ

បើបានជួបបុរស
មានចិត្តស្មោះបែរជាក្បត់
ចោលបេះដូងបរិសុទ្ធ
ឱ្យតក់ស្លុតព្រាត់កំព្រាៗ

លុះដល់ពេលបុរស
ឈាមហូរខ្សោះរស់គ្រាំគ្រា
លើកដៃសូមស្មារលា
នោះបែរជានារីដេញៗ

ឱ! ស្រមោលនារី
រាល់នាទីលជន្លេញ
បុរសទុក្ខទោម្នេញ
តាមរត់ចេញ ចេញរត់តាម៕

យើងចាប់ផ្តើមជាមួយនឹងក្តីស្រឡាញ់
តែហេតុអ្វីយើងត្រូវបញ្ចប់វាដោយក្តីគំនុំទៅវិញ ?
បងមិនយល់ទេ !

បិសាចក្រមុំ

# ស្ទឹងកម្ម

ភ្លៀងសើមអាកាស ពពកដេរដាស
ដិតដាមវិបត្តិ ឥន្ទធ្នូសាកពណ៌
រលាយសូន្យបាត់ ដូចស្រីព្រាត់ខ្វាត់
ចាកឆ្ងាយបងហើយៗ

ទងផ្ការលួយ មែកឈើអស់ត្រួយ
សត្វពួនលែងឆ្លើយ ព្យុះលេបមាត់ច្រាំង
ទូកលែងបកក្រោយ លង់ចោលកោះត្រើយ
លិចក្នុងស្ទឹងកម្មៗ៕

*យួន សូដា*

មេឃគ្មានភ្លៀងទេ
តែត្របកភ្នែកខ្ញុំរលឹមជាប់ៗ
ដួងចិត្តខ្ញុំថ្លួចថ្ងូរលាន់ដូចជាផ្គររន្ទះនាវសន្តរដូវៗ
ទ្ភ្រិក្សដ៏ចម្លែកកើតមានចំពោះស្នេហាខ្ញុំៗ

បិសាចក្រមុំ

# ផ្កាស្មៅ

ស្នឹងហូរសំដៅ នាំយកផ្កាស្មៅ
រសាត់ទៅឆ្ងាយ កុកហើរកាត់ស្នឹង
តឹងទ្រូងសោកស្ដាយ ស្លឹកឈើទាំងឡាយ
ចាកទងក្រៀមស្វិតៗ

ផ្កាស្មៅហូរចុះ កុកកុំស្រណោះ
ព្រោះព្រហ្មលិខិត សាយ័ណ្ហផុតហើយ
មេឃក៏ងងឹត ចិញ្ចឹមដួងចិត្ត
រំពឹងស្អែកថ្មីៗ៕

*ឃួន ស្វិតា*

ការបាត់បង់រូបអូន
គឺជាការចាប់កំណើតឡើងវិញនៃព្រលឹងបងៗ
បងសែនស្តាយពេលវេលារបស់បងកន្លងមក
ក្រៃលែង
តែបងពិតជាអរគុណអូនខ្លាំងណាស់
ដែលធ្វើឱ្យបងចេះស្រឡាញ់ខ្លួនឯង
ជាជាងឱបក្រសោបនារីដែលគ្មានបេះដូង
ដូចជារូបអូនៗ

បិសាចក្រមុំ

# ថ្ងៃលិចនៅចំការឈូក

ចំការឈូក ធ្លាប់ជួបគ្នា គ្រាដំបូង
ចំការឈូក ខ្យល់រំលង ជ្រោងររិច
ចំការឈូក មេឃស្រឡះ ច្បាស់ថ្ងៃលិច
ចំការឈូក នឹកជានិច្ច ភ្លេចមិនបានៗ

ស្លឹកឈូកស្រស់ ពណ៌បៃតង ក្នុងស្រះធំ
ស្លឹកឈូកស្រស់ ហាក់ក្រាលព្រំ រុំព័ទ្ធឋាន
ស្លឹកឈូកស្រស់ ត្រីហក់ហែល ឆ្វៃលកម្សាន្ត
ស្លឹកឈូកស្រស់ រលកច្រាន ប្រាណទទាក់ៗ

ផ្កាឈូករីក ត្របកស បរិសុទ្ធ
ផ្កាឈូករីក ក្លិនជ្រាបជ្រួត ស្ងួតត្រជាក់
ផ្កាឈូករីក លាស់ឆ្ងាយពី ទីទឹករាក់
ផ្កាឈូករីក ក្រពុំលាក់ ទាក់ចិត្តស្នេហ៍ៗ

*យឿង សុខា*

បងស្នេហ៍ឈ្យូក ព្រោះឈ្មោះស្រី ឆ័យបទុម
បងស្នេហ៍ឈ្យូក ព្រោះអារម្មណ៍ ម៉ុមស្នេហ៍ដែរ
បងស្នេហ៍ឈ្យូក ហ៊ានបេះជូន អូនថ្នមថៃ
បងស្នេហ៍ឈ្យូក បានត្រឹមតែ ក្បែរស្រមៃ។

រាល់ពេលសេចក្ដីឈឺចាប់សង្កត់មកលើទ្រូងខ្ញុំម្ដងៗ
ខ្ញុំដឹងថាវាពិតជាមានទម្ងន់ធ្ងន់ក្រៃលែង
ដូចជាមេឃបាក់សង្កត់មកដូច្នោះៗ
ខ្ញុំមានអារម្មណ៍ថា
ថ្ងៃស្អែកហាក់មិនងាយមកដល់ឡើយ
ហើយថ្ងៃនេះហាក់មិនងាយឆ្លងផុត
ប៉ុន្តែខ្ញុំនៅតែជឿថា
ខ្ញុំនឹងឆ្លងផុត
ហើយសេចក្ដីឈឺចាប់នឹងរលាយបាត់ទៅៗ
ខ្ញុំនឹងទុកពេលវេលាយ៉ាងគ្រប់គ្រាន់
ដើម្បីឱ្យអ្វីៗចាកចេញទៅដោយសន្សឹមៗថ្នមៗ
មិនមានការបង្ខំអ្វីទាំងអស់
គឺដូចជាការទុំជ្រុះទៅនៃស្លឹកឈើៗ

*ឃួន សុឃា*

# ខែរងា

ខ្យល់ត្រជាក់ ធ្លាក់ចំហាយ កាយរងា
ចិត្តកំព្រា វារឱបខ្នើយ ឱ្យកក់ក្ដៅ
ឱបជំនួស ព្រោះនៅឆ្ងាយ កាយពាលពៅ
ឱបឃ្យូរទៅ នៅដេកគិត រឹតនឹកស្នេហ៍ៗ

បើសិនបាន ប្រាណនួនល្អង បងច្បាស់ជា
លែងរងា លាខ្នើយឱប ឈប់ដេកក្បែរ
ដេកដណ្ដប់ គ្របតួយសាច់ ធ្មេចប្រួលប្រែ
ដេកទាល់តែ ខែរងា លាបាត់ទៅ៕

អូនសរសើរបងថាឆ្លាតណាស់ៗ
អូនថាបងកេងចំណេញលើមនោសញ្ចេតនា
រវាងយើងទាំងពីរ
ហើយធ្វើពុតជាទួញសោកពេលខកបំណង
ដើម្បីបន្ថែមសម្រស់ឱ្យសំណេររបស់បងៗ
អូនអើយ!
ទាំងសេចក្តីស្រឡាញ់ និងសេចក្តីខកចិត្តរបស់បង
សុទ្ធតែជារឿងពិតៗ
សំណេរនៅក្នុងបទនិពន្ធរបស់បង
គ្រាន់តែជារង្វាន់បន្តិចបន្តួចដែលបងឆ្លាក់ថ្មៃ
ប្រគល់ជូនខ្លួនឯង
ដើម្បីលួងចិត្តនៅពេលអវត្តមាន
នៃភាពថ្នាក់ថ្នមរបស់អូនប៉ុណ្ណោះៗ

*យួង សុងា*

# តំណែងគួរង

បើគេធ្វើឱ្យអូនទឹកភ្នែក
បងចង់រំលែកទុក្ខសោកសៅ
សម្ងួតទឹកភ្នែកអូនឥឡូវ
ឱ្យនៅសល់តែថ្ពាល់ស្រស់ខ្ចីៗ

ឃើញអូនបានសុខបងអស់ចិត្ត
ទោះមិនបានស្និទ្ធរួមមេត្រី
តំណែងតួរងក្រៅទ្រូងស្រី
ក៏បងបេតីស្ម័គ្រអាសា៕

ក្រោយស្នេហាយើងក្ស័យធនទៅ
បងត្រូវបង្ខំចិត្តធ្វើជាឈ្នួញមនោសញ្ចេតនា
ជាមួយនារីជាច្រើន
ដើម្បីស្តារបំណុលខូចចិត្ត
ដែលអូនបានបន្សល់ទុកដល់បងៗ

*យួន សុង*

# នាយភ្ញៀវការ

ខានយល់ភក្ត្រពុំងាររាជយូរថ្ងៃខែឆ្នាំ
បេះដូងបងប្រេះស្រាំមិនទាន់មើលជាផង
នៅអាល័យអាឡោះលួចយំរឿងកន្លង
ថ្ងៃនេះជួបនួនល្អងបងរឹតតែឈឺផ្សា។

បុរសថ្មីស្រីឱបមុខបងទាំងសើចស្រស់
គេជាកូនកម្លោះត្រៀមចូលក្នុងរោងការ
អូនតែងលួចទាក់ទងកាលយើងជាសង្សារ
ទោះមិត្តអូនរាយការណ៍ក៏បងពុំជឿដែរ។

គេស្តុកស្តម្ភមានលុយមានដីរាប់ហិកតា
បងក្រីក្រគ្រួសារហត់នឿយគ្មានពេលល្ហែ
ជើងបងលោតមិនផុតរនាំងវណ្ណៈស្នេហ៍
ប្រាថ្នាអូនទាល់តែទ្រព្យធំព្រោះអូនខ្ពស់។

ធៀបការអូនហុចជូនដូចដាវចាក់ប្រល័យ
ជីវិតបងស្មើរក្ស័យបេះដូងរើបួស
ពីសង្សារក្លាយជាភ្ញៀវការនាមជំនួស
ឱព្រះអើយពីរោះគួរស្តាប់ជាងតន្ត្រី។

*ឈួន សុធា*

ទីនេះហើយដែលយើងធ្លាប់រួមរស់ជាមួយគ្នា
វេលាថ្មីនេះហើយដែលបងពោលពាក្យស្រឡាញ់ៗ
មួយពាន់ដងទៅអូនៗ
ទោះអូនបំភ្លេចក៏បងគ្មានថ្ងៃភ្លេច
ទោះអូនបានក្លាយទៅជាគូសង្សារថ្មីរបស់ប្រុសដទៃ
ទៅហើយ
តែអូននៅតែមាននាមថាជា
អតីតសង្សាររបស់បងជានិច្ចៗ

# បងស្ញើចអូនណាស់

ស្រឡាញ់រូបអូនបងសែនហត់
ទោះខឹងខំអត់តាមចិត្តស្រី
បងខំប្រគល់គ្រប់អ្វីៗ
បេះដូងភក្តីវះជូនស្នេហ៍ៗ

ចុងក្រោយសល់ត្រឹមសម្បកកាយ
ស្នេហ៍អូនក្លែងក្លាយឆ្កួតឡប់ឡែ
បងស្ញើចអូនណាស់អូនពូកែ
ពូកែខាងតែលក់មាយា៕

*យ៉ូង សុខា*

ប្រសិនបើអូនបានដឹងពីទំហំនៃសេចក្តីឈឺចាប់
ដែលលាក់ទុកនៅក្នុងទ្រូងបង
អូនប្រហែលជានឹងអាណិតដល់រូបបងខ្លះ
ហើយអូនក៏ប្រហែលជាមិនឆាប់ក្បត់បង
លឿនដូចពេលនេះដែរៗ
ប៉ុន្តែភាពអាត្មានិយមដ៏ធំធេងរបស់អូន
ប្រហែលជាមិនបង្រៀនអូនឱ្យចេះអាណិតចំពោះ
សេចក្តីឈឺចាប់របស់មនុស្សជាទីស្រឡាញ់ឡើយៗ

# ចិត្តចើក

ចិត្តចើកចើងចុះចាកចេញ
ពិសពុលពុតពេញពោះពាលពៅ
រកឿងរេរាំឫករាងរៅ
ទទូចទាញទៅទុក្ខទាស់ទែងៗ

រោលរាលរួបរឹតរូបរុះរោយ
លោភលន់លាភលុយលេសលះលែង
ខាងខុសខូចខិលខិតខំខែង
លលាមលូកលេងលបលួចលៃៗ

បែកបែរបោះបង់បោកបិទបាំង
រូបរៀមរឹងរាំងរស់រុាំរ៉ៃ
ក្រាបក្រិនក្រៀមក្រំក្រាស់ក្រែលក្រៃ
ដុនដាបដល់ដីដួលដាំដូងៗ។

*ឃ្លួង សូឌា*

មួយថ្ងៃដែលអូនស្រឡាញ់បង
ស្មើនឹងមួយឆ្នាំនៃជីវិតបងលើឋានសួគ៌
តែមួយនាទីដែលអូនក្បត់បង
ស្មើនឹងជីវិតបងទាំងមូលក្នុងឋាននរកៗ

# បិសាចក្រមុំ

ក្រមុំស្អាតដូចផ្ការីកថ្មី
ដូចចន្ទបូរមីលើនភា
ឬដូចអប្សរក្នុងសួគ៌ា
តែចិត្តគឺជាព្រាយបិសាចៗ

យកស្នេហ៍ធ្វើល្បែងក្លែងធ្វើស្មោះ
ក្បត់ហើយសើចស្រស់ប្រុសសុំខ្លាច
ខ្លាំងជាងក្រពើតោកំណាច
ញក់ញី្ញខ្លាំខ្លាចបេះដូងខ្ញុំៗ

ស្អប់ខ្ពើមទ្រូងបងឱបទ្រូងផ្សេង
បងស្ទើរវង្វេងព្រោះទុក្ខធំ
ស្នេហ៍អូនដូចពិសលាយទឹកឃ្មុំ
ឱ្យបងទួញយំស្ទើរមរណាៗ

*ឈួន សុខា*

អាងតែសម្រស់នៅស្រស់ក្មេង
អួនឈ្លក់វង្វេងឫកហ៊ឹហា
បងសូមលាហើយលាស្នេហា
ក្រមុំកាយាចិត្តបិសាចៗ៕

ក្រមុំមិនខុសអ្វីទៅនឹងបាតស្គីនៃកែវភ្នែក
ប៉ុន្តែជាបាតនរកនៃដួងចិត្តបុរសឡើយៗ

*ឃ្លួន សុខា*

# ក្មេងនារី

នារីដូចក្មេង គេនាំឱ្យលេង
ដោយល្បែងស្នេហា គេច្រៀងបំពេរ
ដោយពាក្យសន្យា គេថ្នមរក្សា
ដោយកាមវិធីៗ

ឬកពាម្ទិកម្ទក់ ចិត្តស្រាលខ្យល់បក់
ផ្លាស់គ្រប់នាទី អាងតែទឹកភ្នែក
ហូរជន់ធរណី អោយគេរក់រី
ដាក់ខ្លួនចាញ់ប្រៀបៗ

តែក្មេងនេះណា អំណាចអស្ចារ្យ
ស្ដេចពុំអាចផ្ទៀប គ្រប់គ្រងលោកិយ
ដោយចិត្តសុភាព តែប្រុសដួលរាប
ស្លាប់តាយហោងបាន។

ខ្ញុំក្រឡេកឃើញផ្ទះបុរសៗរាប់មិនអស់
រាប់ចាប់តាំងពីឋានៈរាស្ត្រដល់ក្សត្រ
ត្រូវបានកប់នៅត្រង់កូនភ្នំទាំងពីរ
និងមាត់ជ្រោះរបស់នារីៗ
ឱ!នារីក្នុងលោកអើយ!
ដែនដីរបស់អ្នកពិតជាស្រស់ស្អាតបង្កប់ដោយគ្រោះ
ថ្នាក់សាហាវពេកហើយៗ
រូបអ្នកមិនខុសពីព្រះសិវៈ
ដែលបង្កើតលោកផង
និងបំផ្លាញលោកផងនោះទេៗ

*យឿង សុធា*

# ទ្រាំ

ទ្រាំធ្វើជាសើចតែមិនទទួញយំ
ទោះទុក្ខប៉ុនភ្នំយល់ប៉ុនសំឡី
ទ្រាំធ្វើគថ្លង់តែមិនជេរស្តី
ទោះគេខុសក្តីយល់យើងអ្នកខុសៗ

ទ្រោះធ្វើជាល្ងង់តែមិនសងសឹក
ទោះចិត្តនៅនឹកខឹងរាប់មិនអស់
ទ្រោះធ្វើឆ្កួតឡប់តែមិនឈ្លោះឈ្លោះ
ទោះគេទ្រគោះតោះតើយយ៉ាងណាៗ

ទ្រាំស្ងៀមខាំមាត់សង្កត់ដួងចិត្ត
បណ្តុះគំនិតបង្កើតវាសនា
ទ្រាំដើរលើផ្លូវទៅទាំងឯកា
រង់ចាំប្រាថ្នាក្លាយជាការពិតៗ

ខូចចិត្តយូរៗទៅក្លាយទៅជាភាពសាមញ្ញៗ
បងហាក់ឆ្ងាញ់នឹងសេចក្តីទុក្ខសោក
ដែលអូនបានបន្សល់ទុកជាមរតក
ក្រោយមរណកាលនៃស្នេហាយើងៗ

យួន សុខា

# ជនសំណល់

ខ្ញុំស្រែកខ្សាវៗអស់កម្លាំង
នេត្រាស្រវាំងងងឹតអស់
ជីវិតខ្ញុំដូចស្លាប់ទាំងរស់
បេះដូងរបួសមើលពុំជាៗ

អូនមើលងាយថោកស្នេហាបង
ផ្កាញ់ផ្អាលឌឺដងឱ្យគ្រាំគ្រា
ស្នាមថើបអូនភ្លេចឈប់នឹកនា
រូបបងត្រឹមជាជនសំណល់ៗ

ក្រោយអូនខ្ចាក់បេះដូងរបស់បងចោល
វាបានក្លាយជាកម្មួតដែលនារីដទៃខ្ទើមរអើមៗ

*យួង សូដា*

# ស្តាយចិត្តកម្លោះ

ហែកទ្រូងរូងយកថ្លើមប្រម៉ាត់
បេះដូងសម្ងាត់កាត់ជូនស្រី
លោហិតហូរស្រក់បញ្ជាក់ន័យ
សច្ចាភក្ដីជូនស្នេហ៍ពិតៗ

ខំខ្ទប់ត្រចៀកធ្វើមិនឮ
ខំបិទភ្នែកភ្លឺឱ្យងងឹត
ទោះមានគេតាមទាមទារស្និទ្ធ
ក៏បងទាញបិទទ្វារស្នេហាៗ

ដ្បិតរូបបងស្ម័គ្រតែស្រីស្រស់
ដូចព្រះរាមស្មោះតែសីតា
បេះដូងធ្លាប់រឹងជាងសិលា
ប្រែជាឈើផ្សាចេះទន់ភ្លន់ៗ

ស្តាយអើយសែនស្តាយចិត្តកម្លោះ
មិនគួរជួបសោះស្នេហ៍ទារុណ
ចិត្តស្មោះធ្លាប់ថៃ្ងកាលគ្រាមុន
គ្រានេះលិចជន់ក្នុងភក់ជ្រាំ ៗ

*យឿន សុជា*

បងចង់តែរត់ឱ្យផុតផែនដី

ហើយមុជឱ្យកប់ជ្រៅហួសបាតមហាសមុទ្រ

ដើម្បីគេចចេញពីសេចក្ដីឈឺចាប់ទាំងឡាយៗ

បងចង់តែសម្រក់ទឹកភ្នែកប្រជែងនឹងទឹកជ្រោះ

ដែលកំពុងជន់ខ្លាំង

ដើម្បីហូរនាំភាពក្បត់របស់អូន

ទៅកប់ចោលឱ្យបាត់ពីលោកិយនេះៗ

បិសាចក្រមុំ

# ស្មោះប៉ុណ្ណាទៀត?

ស្មោះប៉ុណ្ណឹងហើយ    ឱមាសស្នេហ៍អើយ
ម្ដេចឡើយនៅក្បត់    ក្រែងអូនប្រាថ្នា
ស្នេហាបរិសុទ្ធ    លិខិតសម្បថ
សច្ចាថាស្មោះៗ

បងខំថ្នាក់ថ្នម    ទោះកាយឈឺស្គម
មិនត្អូញត្អែរសោះ    ព្រលប់រំឃំ
ជាយដៃនស្រណោះ    ស្លឹកឈើក្រៀមក្រោះ
ហូតអស់ទឹកភ្នែកៗ

ស្មោះប៉ុណ្ណាទៀត    ឬប្រុសចោលម្សៀត
សមរងអម្រែក    លើកដៃចាញ់ហើយ
ចិត្តស្រីពស់វែក    សូមឱ្យថ្ងៃស្អែក
ខានយល់រូបថ្លៃៗ៕

*យួន សូដា*

បុរសក្នុងលោក
ត្រូវតែគិតឱ្យដូចជាខ្ញុំតែងតែគិតថា
" បើគេចាកចោលខ្ញុំ នោះមានន័យថា
គេគ្មានសំណាងបានបុរសល្អដូចជាខ្ញុំធ្វើប្ដី
ហើយបើគេក្បត់បេះដូងបរិសុទ្ធរបស់ខ្ញុំ
នោះមានន័យថាខ្សែភ្នែករបស់គេអន់ណាស់ៗ
គេកំពុងតែបោះចោលគ្រាប់ពេជ្រទៅឱ្យអ្នកដទៃៗ "

# មិនមែនសង្សារបងទេ

វាយោចម្លែកស្ងប់ស្ងាត់ មេឃជ្រុះផ្កាយបាត់
លេបចន្ទទុកក្នុងពពក ៗ

សមុទ្រលែងមានរលក ឆ្នេរខ្សាច់ហៅរក
ដានជើងស្រីឱ្យត្រឡប់ ៗ

ឱរាកវីតឹងថប់ លាក់ន័យបង្កប់
និទានចុកចាប់ទារុណ ៗ

ពាក្យស្រីពោលខុសពីមុន លែងចេះទន់ភ្លន់
លែងទុកប្រុសក្នុងកែវភ្នែក ៗ

ចូលចិត្តតែឈ្លោះប្រកែក និយមពាក្យបែក
ចោទបងដូចជនឧក្រិដ្ឋ ៗ

*យួង សុខា*

ស្នេហ៍ស្មោះខ្សឹបប្រាប់ដួងចិត្ត ថាស្រស់វមិត្រ
មិនមែនសង្សារបងទេៗ

សង្សារបងណាមាសមេ នាងតែងបំពេរ
ផ្កាក់ថ្មមផ្អែមល្ហែមបរិសុទ្ធៗ

នាងមានចិត្តស្មោះបំផុត ពុំដែលចេះក្បត់
សន្យាដូចជាអូនឡើយៗ

ឱ!សង្សារពីមុនអើយ បើឮសូមឆ្លើយ
វិលមកសាងស្នេហ៍ជាថ្មីៗ

ជីវិតរស់ដូចអរធី មិនគួររូបស្រី
នៅកាយតែចិត្តខុសមុនៗ៕

ប្រសិនបើទីណាមានដាក់លក់ស្នេហាស្មោះ
ខ្ញុំនឹងទិញដូរដោយជីវិតតែមួយរបស់ខ្ញុំ។

# កុំសូមទោសអី !

សុខៗផ្ញើសារប្រាប់ថាសូមទោស
អូនថាខ្លួនខុសដែលសុំបែកបង
ថែមឱ្យបំភ្លេចរឿងរ៉ាវកន្លង
ពាក្យពេចន៍សាសងលុបឈប់ចងចាំៗ

យកលេសដោះសាថាមិនសក្តិសម
វញ្ញស្នេហ៍បង្ខំឱ្យធ្លាក់ជ្រោះកម្ម
បេះដូងបងដូចគេដំឱ្យស្រាំ
ព្រោះតែបណ្ដាំឱ្យរកអ្នកថ្មីៗ

នេះឬសន្យាធ្លាប់ស្បថថាស្មោះ
ឥឡូវប្រែអស់រុះរោយអត្ថន័យ
បើអស់ចិត្តហើយកុំសូមទោសអី
ពៅគ្មានទោសពៃរ៍បន្តិចសោះណាៗ

តាមពិតបងទេគឺជាអ្នកខុស
មានស្នាមកំហុសព្រោះខ្វាក់នេត្រា
មើលគេច្រឡំស្មានតែសង្សារ
ខំលង់ចិន្តាផ្ញើទាំងជីវិត។

ពីពេលនេះទៅសូមពៅបានសុខ
កុំឱ្យយល់មុខនាំបងឈឺចិត្ត
ផ្កាស្នេហ៍រុះរោយចាកទងក្រៀមស្វិត
អូនអើយកុំគិតថាបងបកក្រោយ៕

*ឃឿន សុធា*

ពេលខ្លះពាក្យសុំទោសរបស់អូន
ពុំដែលឮចំពេលដែលបងត្រូវការវាឡើយ
វាមកចំតែពេលដែលត្រចៀករបស់បងទាំង
សងខាងបានបិទអស់ទៅហើយ
ហើយទីបំផុតពាក្យថាស្តាយក្រោយរបស់អូន
ក៏មកចំពេលដែលបេះដូងបងកំពុងលង់លក់
ដូចគ្នាៗ
អូនយឺតយ៉ាវពេកហើយ!
ដឹងទេ?

ចូរទុកសេរីភាពឱ្យមនុស្សដែលយើងស្រឡាញ់ ប្រៀបដូចយើងឈរមើលបក្សីហើរលេងយ៉ាងសប្បាយលើមេឃា !

ចូរបណ្តោយឱ្យរឿងរ៉ាវនៃសេចក្តីស្នេហា ប្រព្រឹត្តទៅដោយឥតបង្ខំប្រៀបដូចជាយើងឈរមើលខ្សែទឹកហូរទៅតាមដំណើរធម្មជាតិពីលើចុះក្រោម !

ចូរញញឹមត្រេកអរទាំងសេចក្តីសុខសាន្ត និងសេចក្តីទុក្ខសោក ដែលមនុស្សជាទីស្រឡាញ់ផ្តល់ឱ្យ ប្រៀបដូចជាភ្នំខ្ពស់ដែលមិនបដិសេធនូវក្លិនពិដោរនៃលម្អងផ្កា និងស្លឹកឈើរលួយស្អុយកប់នៅក្នុងស្រទាប់ដី !

*យឿង សុខា*

អ្វីដែលជារបស់យើង វានឹងនៅតែជារបស់យើង ឯអ្វីដែលមិនមែនជារបស់យើង វាគង់តែមិនមែនជារបស់យើងដដែល។

បើគេស្ម័គ្រនៅជួបជុំ ឬផ្ដល់ក្ដីស្រឡាញ់តបមកយើង ត្រូវទទួលថ្នាក់ថ្នមដោយដៃទាំងពីរ និងបេះដូងដ៏បរិសុទ្ធមួយ ហើយចាត់ទុកថា ជាព្រេងសំណាង។

បើគេត្រឡប់ក្រោយចាកចោល ឬរំលងទៅមុខហួសយើង ត្រូវបួងសួងជូនពរសេចក្ដីសុខដោយដៃទាំងពីរ និងខួរក្បាលដ៏សុទិដ្ឋិនិយមមួយ ហើយចាត់ទុកថាជាព្រហ្មលិខិត។

# បិសាចក្រមុំ

ក្រមុំស្អាតដូចផ្ការីកថ្មី
ដូចចន្ទមូរយីលើនភា
ឬដូចអេប្សរក្នុងសួគ៌ា
តែចិត្តគឺជាព្រាយបិសាច។
យកស្នេហ៍ធ្វើល្បែងក្លែងធ្វើស្មោះ
ក្បត់ហើយសើចស្រស់ប្រុសសុំខ្លាច
ខ្លាំងជាងក្រពើតោកំណាច
ញាក់ញើខ្ញុំខ្លាចបេះដូងខ្ញុំ។
ស្អប់ខ្ពើមទ្រូងបងឱបទ្រូងផ្សេង
បងស្ទើរវង្វេងព្រោះទុក្ខធំ
ស្នេហ៍អូនដូចពិសលាយទឹកឃ្មុំ
អោយបងទួញយំស្ទើរមរណា។
អាងតែសម្រស់នៅស្រស់ក្មេង
អូនឈ្លក់វង្វេងឫកហ៊ឺហា
បងសូមលាហើយលាស្នេហា
ក្រមុំកាយាចិត្តបិសាច៕